ថ្ងៃ សុក្រ ទី 6 ខែកុម្ភៈ ឆ្នាំ 2015

## ថ្លៃប្រណិត៖ ជំនួញឈើមានតម្លៃខុសច្បាប់របស់កម្ពុជាជាមួយចិន

### សេចក្តីសង្ខេប

ការរក់និយមសង្ហារឹម *ហុងមុ* ពីឈើក្រញូងប្រណិត បានធ្វើឲ្យកើនឡើងប្រតិបត្តិការជំនួញឈើខុសច្បាប់រាប់លានដុល្លារក្នុងប្រទេសកម្ពុជា។ *ថ្លៃប្រណិត* គឺជាលទ្ធផលនៃការស៊ើបអង្កេតសម្ងាត់រយៈពេលប្រាំបីខែ អំពីការមមាញឹកចំពោះឈើដ៏មានតម្លៃចុងក្រោយរបស់ប្រទេសកម្ពុជា។ របាយការណ៍កត់ត្រាអំពីរបៀបដែលមនុស្សម្នាក់ - មហាសេដ្ឋីកម្ពុជា ឧកញ៉ា ទ្រី ភាព - គឺជាអ្នកដឹកនាំនៃបណ្តាញការកាប់ឈើខុសច្បាប់រួមគ្នាទាំងអស់ ដែលផ្អែកលើការសមគំនិតរបស់មន្ត្រីរដ្ឋ និងភ្នាក់ងារអនុវត្តច្បាប់ដែលបានបង្កើតឡើងដើម្បីលួចប្លន់ឈើកម្រដូចជា ក្រញូង (Dalbergia cochinchinensis) ជួញឈើដោយលួចលាក់ទូទាំងប្រទេស និងផ្ទុកឈើទាំងនោះលើទូកឆ្ពោះទៅទីក្រុងហុងកុង។

ច្បាប់ដ៏តឹងរ៉ឹងការពារប្រភេទពូជឈើកម្រ និងប្រណិត បានចូលជាធរមាន នៅឆ្នាំ 2002 អំឡុងការប្រឆាំងជំទាស់នឹងការបំផ្លិចបំផ្លាញព្រៃឈើទ្រង់ទ្រាយធំ ទោះយ៉ាងណាការស៊ើបអង្កេតរបស់យើងបង្ហាញថា ក្រុមហ៊ុន ទ្រី ភាព កំពុងផ្ទុកឈើ រហូតដល់ 900 ម៉ែត្រត្រីគុណលើកប៉ាល់សម្រាប់ការនាំចេញជារៀងរាល់ថ្ងៃ ដែលមានប្រភពធំពីតំបន់ការពារ និងឧទ្យានជាតិរបស់ប្រទេសកម្ពុជា។ ឧកញ៉ា ទ្រី ភាព ដែលពីមុនគឺជាទីប្រឹក្សាផ្ទាល់នាយករដ្ឋមន្ត្រី ហ៊ុន សែន កំពុងធ្វើឲ្យហិនហោចព្រៃដោយច្បាប់ និងដោយស្ថិតក្រោមការការពារនៃការឈូសឆាយដីសម្រាប់កសិ-ឧស្សាហកម្ម (ស្ថិតក្រោមអ្វីដែលហៅថា 'ដីសម្បទានសេដ្ឋកិច្ច')។ គាត់ត្រូវបានប្រគល់ជូនដីសម្បទានធំជាងច្រើនពីកម្រិតកំណត់ស្របច្បាប់ និងហាក់បីដូចជាកំពុងប្រើប្រាស់ដីសម្បទានទាំងនោះ ដើម្បីលាងឈើប្រណិតពីតំបន់ការពារទាំងក្នុង និងក្រៅព្រំប្រទល់សម្បទានរបស់ខ្លួន។ ការកាន់កាប់ឧស្សាហកម្មទ្រង់ទ្រាយធំនេះ គឺកំពុងជួយដឹកនាំប្រភេទពូជឈើ និងសត្វទៅកាន់ការវិនាសហិនហោច ស្របពេលនិងដកហូតពីជនជាតិភាគតិច និងសហគមន៍ដែលពឹងផ្អែកលើព្រៃឈើ នូវធនធានដែលជីវភាពរស់នៅរបស់ពួកគេពឹងផ្អែកលើ។

សក្ខីកម្មពីប្រភពជិតស្និទ្ធក្នុងរដ្ឋាភិបាល និងឧស្សាហកម្ម ដោយរួមទាំងបញ្ជីបៀវត្សរបស់ ទ្រី ភាព បានធ្វើឲ្យអ្នកស្រាវជ្រាវគូសចេញបាននូវប្រព័ន្ធដ៏សាំញ៉ាំនៃសំណូកនិយម និងការសមគំនិត ដោយចាប់ផ្តើមពីអ្នកកាប់ឈើ ឈ្មួញឈើ និងម្ចាស់រោងចក្រអារឈើ ហើយពង្រីកវិសាលភាពទៅដល់ទាហាន ប៉ូលីស បណ្តាអង្គភាពតាមព្រំដែន និងបណ្តាក្រសួង។ អ្នកកាប់ឈើក្នុងបណ្តាញនេះ ហាក់បីដូចជាត្រូវបានផ្តល់ជូននូវការធ្វើដំណើរដោយសុវត្ថិភាព ត្រូវបានការពារពីការរឹបអូសឈើ ឬការពិន័យ។ ក្រុមហ៊ុន ទ្រី ភាព ក៏ត្រូវបានផ្តល់ជូនសិទ្ធិផ្តាច់មុខទិញឈើដែលបានរឹបអូសដោយភ្នាក់ងារអនុវត្តច្បាប់ ដើម្បីលក់បន្តយកចំណេញ។ ដោយបានបញ្ជាក់ថាជាម្នាក់ក្នុងចំណោមឈ្មួញកណ្តាលរបស់ ទ្រី ភាព លោក ហាម ហ៊ុយ គឺជាឧត្តមសេនីយ៍ផ្កាយពីរកងអង្គរក្សកងពលតូចលេខ 70 របស់នាយករដ្ឋមន្ត្រី។ អ្នកស៊ើបការណ៍ជាច្រើនក៏បានពណ៌នាផងដែរអំពីទំនាក់ទំនងដ៏ជិតស្និទ្ធរបស់មហាសេដ្ឋីនេះ ជាមួយមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើ។

លុះត្រាតែត្រូវបានបញ្ជាក់ផ្សេងពីនេះ បើពុំនោះទេ ឈើរបស់ក្រុមហ៊ុន ទ្រី ភាព ពុំគួរត្រូវបានចាត់ទុកថាស្របច្បាប់ឡើយ ដោយសារ៖

- ក្រុមហ៊ុន និងបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន ពង្រាយកម្មករដែលអមដំណើរដោយភ្នាក់ងារអនុវត្តច្បាប់របស់រដ្ឋាភិបាលឲ្យស្វែងរក**ឈើកម្រិតប្រណិត** ដូចជា ក្រញូង ដែលរដ្ឋាភិបាលកម្ពុជាបានហាមប្រាមពីការប្រមូលផល និងការនាំចេញក្នុងឆ្នាំ 2013។ ប្រភេទពូជនេះ ក៏ត្រូវបានការពារក្រោមច្បាប់អន្តរជាតិ ដែលបានចុះបញ្ជីដោយអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទពូជរងគ្រោះថ្នាក់នៃសត្វ និងរុក្ខជាតិក្នុងព្រៃឆ្នាំ 2013។
- ក្រុមហ៊ុនកំពុងធ្វើឲ្យហិនហោចឈើពី**ដីសម្បទានសេដ្ឋកិច្ច** - ដែលជាប្រព័ន្ធភតិសន្យាមួយមានបំណងមិនមែនសម្រាប់ការកាប់ឈើ តែសម្រាប់កសិកម្មទ្រង់ទ្រាយធំ។ គ្មានដីសម្បទានណាមួយរបស់ក្រុមហ៊ុន គួរតែត្រូវបានចាត់ទុកថាស្របច្បាប់ឡើយ ដោយសារពួកគេគ្រប់គ្រងដីព្រៃធំជាងកម្រិតទំហំអតិបរមា និងមិនបានទទួលការប្រឹក្សាសហគមន៍ចាំបាច់។ ដីសម្បទានជិត 20,000 ហិកតាក្នុងឧទ្យានជាតិវីរជ័យ ដែលជាជម្រករបស់ប្រជាជនជនជាតិភាគតិច និងរុក្ខជាតិ ព្រមទាំងប្រភេទពូជសត្វរងគ្រោះថ្នាក់ជាច្រើន ត្រូវបានយកពីក្រុមហ៊ុនវិញដោយរដ្ឋាភិបាលនាចុងឆ្នាំ 2014។
- ក្រុមហ៊ុន ទ្រី ភាព ក៏កំពុងប្រើប្រាស់អាជ្ញាប័ណ្ណដីសម្បទានរបស់ខ្លួន ដើម្បីឈូសឆាយឈើ លើសពីព្រំដែនកំណត់ **លាងឈើមានតម្លៃ និងឈើដែលត្រូវបានការពារ** នៅតំបន់ជុំវិញ។
- ក្រុមហ៊ុនកំពុងនាំចេញឈើក្នុង**ទម្រង់ដែលបានហាមប្រាមសម្រាប់ការនាំចេញ** ដែលមានដូចជា ឈើមិនទាន់កែច្នៃ និងឈើអារអង្កត់ផ្ចិតកម្រាស់ក្រាស់ជាង 25 សង់ទីម៉ែត្រ។

សន្និដ្ឋានថា ទោះបីជាការពិតថាការប្រមូលផល ការដឹកជញ្ជូន និងការនាំចេញកំពុងកើតឡើងស្ថិតក្រោមអាជ្ញាប័ណ្ណរបស់រដ្ឋាភិបាលក៏ដោយ អាជ្ញាធរចេញបទបញ្ញត្តិរបស់កម្ពុជា និងចិន មិនត្រូវមើលរំលងការបំពាន ជាមូលដ្ឋានលើច្បាប់ជាតិ និងអន្តរជាតិរបស់ក្រុមហ៊ុនឡើយ។

ទោះបីជាយ៉ាងនេះក៏ដោយ តម្រូវការឈើកម្ពុជា កំពុងកើនឡើងយ៉ាងឆាប់រហ័ស ជាពិសេសពីក្រៅប្រទេស។ 85 ភាគរយនៃការនាំចេញឈើរបស់ប្រទេសកម្ពុជា គឺឆ្ពោះទៅប្រទេសចិន និងទំហំឈើ *ហុងម៉ុ* ដែលបាននាំចេញទៅទីនេះបានកើនឡើង 150 ភាគរយ រវាងឆ្នាំ 2013 និង 2014។ អ្នកស៊ើបអង្កេតរបស់ គ្លូបល វីតណេស បានតាមដានឈើរបស់ក្រុមហ៊ុន ទ្រី ភាព ពីប្រភពតាមរយៈដេប៉ូឆ្លងកាត់ទៅព្រំដែនវៀតណាម ដោយឆ្លងកាត់អូរយ៉ាដាវ និងទៅកាន់កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ដែលជាកន្លែងឈើត្រូវបានដឹកតាមកប៉ាល់ទៅកាន់ទីតាំងដូចជាទីក្រុងហុងកុងជាដើម។ អំឡុងពេលបួនសប្តាហ៍ អ្នកស្រាវជ្រាវបានសង្កេតឃើញរថយន្តរបស់ក្រុមហ៊ុន ទ្រី ភាព បានចូលទៅកំពង់ផែជាទៀងទាត់ ដោយរាប់ឃើញយ៉ាងហោចណាស់ 30 កុងទេណឺរជារៀងរាល់ថ្ងៃ។

គ្លូបល វីតណេស បានទទួលឯកសារដឹកជញ្ជូនជាច្រើនច្បាប់ សម្រាប់ឈើដែលមានតម្លៃរហូតដល់ 5.6 លានដុល្លារអាមេរិក ដែលបានផ្ញើដោយមិនមានការឆ្លងកាត់ទៅកាន់ក្រុមហ៊ុន Kin Chung Transportation Company ក្នុងទីក្រុងហុងកុង។ ឯកសារមួយបានដកស្រង់ថា រដ្ឋបាលព្រៃឈើ គឺជាអ្នកនាំចេញជំនួសក្រុមហ៊ុន ទ្រី ភាព។ វិក្ក័យប័ត្រ មានកំណែសរសេរដោយដៃដោយមន្ត្រីគយម្នាក់ថាមានតម្លៃទ្វេដងនៃតម្លៃឈើ ដែលការកែប្រែមិនបានបញ្ជាក់ក្នុងលិខិតអនុញ្ញាតនាំចេញគយរបស់ខ្លួនឡើយ។ ឯកសារដែលបានមកពីការពិនិត្យដល់កន្លែងដោយមន្ត្រីគយលើកុងទេណឺរពីរ នៅគំនរនាំចេញដាច់ដោយឡែកពីគ្នាបានបញ្ជាក់ថាពួកវាមាន 'ឈើប្រណិត' ដែលមិនស្របច្បាប់ក្នុងការប្រមូលផលក្នុងប្រទេសកម្ពុជា។ ទោះយ៉ាងណាកុងទេណឺរទាំងពីរ ត្រូវបានអនុម័តសម្រាប់ការនាំចេញ។ ឈើនេះ ក៏ហាក់បីដូចជាត្រូវបាននាំចេញដោយមិនមានលិខិតអនុញ្ញាតគយដែលមានសុពលភាពផងដែរ។ ការបំពាននេះបញ្ជាក់ថា ច្បាប់ជាតិរបស់កម្ពុជាកំពុងត្រូវបានរំលោភមាក់ងាយជាទម្លាប់ នៅដំណាក់កាលនីមួយៗនៃដំណើររបស់ឈើចាប់ពីការប្រមូលផលរហូតដល់ការនាំចេញ ហើយការនាំចេញដែលបានអនុម័តដោយរដ្ឋាភិបាល គួរតែត្រូវបានចាត់ទុកថាមានការសង្ស័យ។

ការស៊ើបអង្កេតអំពីក្រុមហ៊ុន Kin Chung Transportation Company ក្នុងទីក្រុងហុងកុងបង្ហាញថាជា ក្រុមហ៊ុនដឹកជញ្ជូនដែលមានភាគហ៊ុនដើមទុនត្រឹមតែ 2.00 ដុល្លារហុងកុងប៉ុណ្ណោះ ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុនក្នុងអាផាត់ម៉ងមែនស្នាក់នៅ ដែលមិនមានចុះបញ្ជីលំអិតអំពីព័ត៌មានទំនាក់ទំនង ឬមិនមានវត្តមានជាសាធារណៈក្នុងឋានៈជាក្រុមហ៊ុនជំនួញឈើមួយ។ នៅពេលដែលបានទាក់ទងទៅកាន់ នាយករបស់ក្រុមហ៊ុនបានអះអាងបញ្ជាក់ថាមិនស្គាល់ក្រុមហ៊ុន ទ្រី ភាព មិនមានការពាក់ព័ន្ធក្នុងការនាំចូលឈើដែលបានរៀបរាប់ពីខាងលើពីប្រទេសកម្ពុជា ក្នុងខែ មីនា ឆ្នាំ 2014 ហើយមិនមានយោបល់ ពីមូលហេតុដែលក្រុមហ៊ុនរបស់ខ្លួន បានពាក់ព័ន្ធនឹងការដឹកជញ្ជូននេះ។ ការឆ្លើយតបដូចនេះ គ្រាន់តែបង្កើនបន្ថែមការសង្ស័យអំពីភាពស្របច្បាប់នៃអាជីវកម្មជំនួញឈើរបស់ឧកញ៉ា ទ្រី ភាព តែប៉ុណ្ណោះ។

វិធានការណ៍បន្ទាន់ខាងក្រោម គឺត្រូវការចាំបាច់ដោយរដ្ឋាភិបាលកម្ពុជា និងចិន ព្រមទាំងបណ្តាភាគីរដ្ឋនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទពូជរងគ្រោះថ្នាក់ នៃសត្វ និងរុក្ខជាតិក្នុងព្រៃដើម្បីបញ្ចៀសការបំផ្លិចបំផ្លាញកន្លែងរស់នៅរបស់ព្រៃឈើសំខាន់ៗ និងជីវភាពរស់នៅរបស់សហគមន៍ដែលពឹងផ្អែកលើពួកវា៖

1) អនុសាសន៍ជូនរាជរដ្ឋាភិបាលកម្ពុជា៖

- ស៊ើបអង្កេតទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ទ្រី ភាព និងអង្គភាពជាបុត្រសម្ព័ន្ធទាំងអស់រកមើលសកម្មភាពខុសច្បាប់ និងការប្រតិបត្តិតាមច្បាប់ជាតិ។ ក្នុងករណីសកម្មភាពខុសច្បាប់ត្រូវបានរកឃើញ សូមចាត់វិធានការណ៍លុបអាជ្ញាប័ណ្ណរបស់រដ្ឋាភិបាលពាក់ព័ន្ធ ហើយផ្តួចផ្តើមការកាត់ទោសអ្នកទាំងឡាយដែលទទួលខុសត្រូវ។ ដោយការរង់ចាំលទ្ធផលនៃការស៊ើបអង្កេតនេះ ក្រុមហ៊ុន ទ្រី ភាព គួរតែត្រូវបានទប់ស្កាត់ពីការទទួលបានអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតបន្ថែមទៀត (ដោយរួមទាំងការនាំចេញឈើ) ហើយគួរត្រូវបានដកចេញពីការចូលរួមក្នុងការដេញថ្លៃឈើ
- បង្កើតការស៊ើបអង្កេតតាមប្រព័ន្ធតុលាការ អំពីការចេញលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណដោយអាជ្ញាធររដ្ឋាភិបាលផ្សេងៗ ដែលបានផ្តល់ជូនក្រុមហ៊ុន ទ្រី ភាព ឲ្យប្រមូលផល ប្រមូល ជួញដូរ និងនាំចេញប្រភេទពូជឈើប្រណិត
- ចាត់វិធានការណ៍បន្ទាន់ ដើម្បីពង្រឹងច្បាប់ស្តីពីព្រៃឈើ និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ព្រមទាំងពង្រឹងបទបញ្ញត្តិដើម្បីការពារប្រភេទពូជឈើកម្រ និងរងគ្រោះថ្នាក់
- ដាក់ដេញថ្លៃផ្តាច់ឈើដែលរឹបអូសបានបច្ចុប្បន្នទាំងអស់ ដែលនឹងរៀបចំដោយក្រសួងកសិកម្ម រដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន តាមរយៈដំណើរការដេញថ្លៃជាសាធារណៈ ដោយត្រួតពិនិត្យដោយអ្នកសង្កេតការណ៍ឯករាជ្យ និងដាក់ប្រាក់ចំណូលដែលរកបានក្នុងមូលនិធិដែលត្រូវប្រើប្រាស់ដើម្បីការពារប្រភេទពូជឈើកម្រ និងរងគ្រោះថ្នាក់។ ដោយការអនុវត្តតាមនេះ សូមធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើឲ្យចែងថា ឈើដែលរឹបអូសបាននាពេលក្រោយត្រូវកម្ទេចចោលភ្លាមៗ
- បន្ថែមការគាំទ្រ ទាំងគោលនយោបាយ និងការអនុវត្ត កិច្ចខិតខំប្រឹងប្រែងរបស់បណ្តាក្រុមសហគមន៍មូលដ្ឋានដែលរួមទាំងប្រជាជនជនជាតិភាគតិច ដើម្បីការពារព្រៃឈើរបស់ខ្លួនពីការកាប់ឈើខុសច្បាប់ និងសកម្មភាពអចីរភាពផ្សេងទៀត។ ជាពិសេស កំណត់អាទិភាពការផ្តល់មូលនិធិ និងធនធាន ដើម្បីបង្កើនល្បឿនការទទួលស្គាល់តំបន់ព្រៃសហគមន៍ និងការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិភាគតិច
- ចាត់វិធានការណ៍ដើម្បីធានាថា ប្រទេសកម្ពុជាប្រតិបត្តិតាម CITES ដោយចុះបញ្ជីក្រញូងយ៉ាងយូរបំផុតចុងឆ្នាំ 2015 ដោយរួមទាំងការទទួលខុសត្រូវ និងការបោះពុម្ពផ្សាយ ការសិក្សាវិទ្យាសាស្ត្រអំពីបំណែងចែកប្រភេទពូជ និងការផ្តល់ជូនការគាំទ្រចាំបាច់សម្រាប់អាជ្ញាធរគ្រប់គ្រង CITES ប្រចាំប្រទេសកម្ពុជា ក្នុងការចេញអាជ្ញាប័ណ្ណនាំចេញឲ្យស្របតាមបទបញ្ញត្តិរបស់ CITES។

2) អនុសាសន៍ជូនសាធារណរដ្ឋប្រជាមានិតចិន៖

- ចាត់វិធានការណ៍ភ្លាមៗបញ្ឈប់ការនាំចូលប្រភេទពូជឈើហុងមុទាំងអស់ពីប្រទេសកម្ពុជា ដែលមានក្នុងបញ្ជីប្រភេទពូជឈើកម្ររបស់រដ្ឋាភិបាលកម្ពុជា

- ជាវិធានការណ៍បណ្ដោះអាសន្ន សូមធ្វើឲ្យប្រាកដថាគោលការណ៍ណែនាំស្ដីពីជំនួញ និងការវិនិយោគឈើនាពេលអនាគតរបស់រដ្ឋបាលព្រៃឈើរដ្ឋ រួមមាននូវសេចក្ដីថ្លែងការណ៍ច្បាស់លាស់ថា បណ្ដាក្រុមហ៊ុនចិនដែលនាំចូល ជួញដូរ និងកែច្នៃឈើ មិនត្រូវទិញឈើខុសច្បាប់ និងថាបណ្ដាក្រុមហ៊ុនដែលប្រើប្រាស់ឈើពីតំបន់មានហានិភ័យខ្ពស់ ត្រូវអនុវត្តការត្រួតពិនិត្យដោយយកចិត្តទុកដាក់ម៉ត់ចត់លើសង្វាក់ផ្គត់ផ្គង់របស់ខ្លួន។ ការត្រួតពិនិត្យដោយយកចិត្តទុកដាក់នេះ គួររួមបញ្ចូលទាំងការឲ្យបណ្ដាក្រុមហ៊ុនរាយការណ៍ជាសាធារណៈ អំពីការត្រួតពិនិត្យដែលខ្លួនអនុវត្ត និងលទ្ធផលរកឃើញដែលការត្រួតពិនិត្យទាំងនេះទទួលបានផងដែរ។
- ឧទ្ទេសនាមបទបញ្ញត្តិដែលហាមប្រាមការនាំចូល ការជួញដូរ និងការកែច្នៃឈើដែលបានប្រមូលផលខុសច្បាប់ និងផលិតផលដែលបានពីឈើនេះ ហើយដែលរួមមាននូវសេចក្ដីតម្រូវឲ្យបណ្ដាក្រុមហ៊ុនដែលប្រើប្រាស់ឈើពីតំបន់មានហានិភ័យខ្ពស់ ឲ្យអនុវត្តការត្រួត ពិនិត្យដោយយកចិត្តទុកដាក់លើសង្វាក់ផ្គត់ផ្គង់របស់ខ្លួន។ ការត្រួតពិនិត្យដោយយកចិត្តទុកដាក់នេះ គួររួមបញ្ចូលទាំងការឲ្យបណ្ដាក្រុមហ៊ុនរាយការណ៍ជាសាធារណៈ អំពីការត្រួតពិនិត្យដែលខ្លួនអនុវត្ត និងលទ្ធផលរកឃើញដែលការត្រួតពិនិត្យទាំងនេះទទួលបានផងដែរ។

3) អនុសាសន៍ជូនអាជ្ញាធរនៃតំបន់រដ្ឋបាលពិសេសហុងកុង៖
- ចាត់វិធានការណ៍ភ្លាមៗបញ្ឈប់ការនាំចូលប្រភេទពូជឈើហុងមុទាំងអស់ពីប្រទេសកម្ពុជា ដែលមានក្នុងបញ្ជីប្រភេទពូជឈើកម្ររបស់រដ្ឋាភិបាលកម្ពុជា
- ចាត់វិធានការណ៍បន្ទាន់ដើម្បីឧទ្ទេសនាមបទបញ្ញត្តិដែលហាមប្រាមការនាំចូល ការជួញដូរ និងការកែច្នៃឈើដែលបានប្រមូលផលខុសច្បាប់ និងផលិតផលដែលបានពីឈើនេះចូលទីក្រុងហុងកុង ហើយដែលរួមមាននូវសេចក្ដីតម្រូវឲ្យបណ្ដាក្រុមហ៊ុនដែលប្រើប្រាស់ឈើ ពីតំបន់មានហានិភ័យខ្ពស់ ឲ្យអនុវត្តការត្រួតពិនិត្យដោយយកចិត្តទុកដាក់លើសង្វាក់ផ្គត់ផ្គង់របស់ខ្លួន។ ការត្រួតពិនិត្យដោយយកចិត្តទុកដាក់នេះ គួររួមបញ្ចូលទាំងការឲ្យបណ្ដាក្រុមហ៊ុនរាយការណ៍ជាសាធារណៈ អំពីការត្រួតពិនិត្យដែលខ្លួនអនុវត្ត និងលទ្ធផលរកឃើញដែលការត្រួតពិនិត្យទាំងនេះទទួលបានផងដែរ។
- ស៊ើបអង្កេតប្រតិបត្តិការរបស់បណ្ដាក្រុមហ៊ុនជួញដូរឈើ ដែលមានមូលដ្ឋាននៅទីក្រុងហុងកុងដូចជា ក្រុមហ៊ុន Kin Chung Transportation Company និងធ្វើឲ្យប្រាកដថាបណ្ដាក្រុមហ៊ុនទាំងនោះនាំចូលតែឈើដែលមានប្រភពស្របច្បាប់ប៉ុណ្ណោះ។

4) អនុសាសន៍ជូនបណ្ដាភាគីនៃអនុសញ្ញាស្ដីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទពូជរងគ្រោះថ្នាក់ នៃសត្វ និងរុក្ខជាតិក្នុងព្រៃ៖
- ដកចេញនូវការលើកលែងក្នុងបញ្ជីក្រញូងបច្ចុប្បន្នក្នុងឧបសម្ព័ន្ធ II ដែលមានន័យថា មិនមែនរាល់ប្រភេទឈើកែច្នៃទាំងអស់នៃប្រភេទពូជនេះ ត្រូវបានគ្របដណ្ដប់ (ត្រូវបានស្គាល់ផ្សេងពីនេះថាជាសេចក្ដីអធិប្បាយស្ដីពីការកម្រិតប្រាំ)
- ពង្រីកវិសាលភាពបញ្ជីក្នុងឧបសម្ព័ន្ធ II ដើម្បីបញ្ចូល នាងនួន *[Burmese Rosewood (Dalbergia bariensis)]* និងថ្នង់ *[Burmese Padauk (Pterocarpus macrocarpus Kurz)]*។